Employment Plus

Parent Pathways

An Australian Government Initiative

# ការប្តេជ្ញាចិត្តសំខាន់ៗលើសេវាកម្ម

## អំពីយើង

Employment Plus ជាផ្នែកមួយនៃអង្គការ The Salvation Army ដែលជាចលនាសាសនាគ្រីស្តអន្តរជាតិមួយបានជួយដល់ប្រជាជនអូស្ត្រាលីលើសេវាកម្មជាច្រើនប្រភេទតាំងពីឆ្នាំ 1880 មក។

## សេវាកម្ម

អ្នកផ្តល់ជំបូន្មានផ្ទាល់ខ្លួនម្នាក់ជួយដល់មាតាបិតាពេញមួយដំណើរការជាមួយយើង ដោយស្វែងយល់ពីចំណុចខ្លាំង បំណងប្រាថ្នា និងបញ្ហាប្រឈមនានា រួមមានការជួយរៀបចំផែនការ តាមដាន និងសម្រេចបានរាល់ជំហានឆ្ពោះទៅរកគោលដៅដែលបានកំណត់។ អ្នកផ្តល់ជំបូន្មានអាចផ្តល់ជំនួយគាំទ្រតាមរយៈការជួបផ្ទាល់ តាមអនឡាញ និងតាមទូរសព្ទ។ យើងមានផ្តល់ជូនសកម្មភាពសិក្សាជាក្រុម បណ្តាញទំនាក់ទំនងរវាងមិត្តភក្តិ និងការជួយសម្រួលឱ្យទទួលបានសេវាកម្មនៅតាមសហគមន៍។ យើងខ្ញុំធ្វើការវាយតម្លៃលើការរីកចម្រើន និង កម្រិតនៃការពេញចិត្តរបស់អាណាព្យាបាលម្នាក់ៗចំពោះសេវាកម្ម ព្រមទាំងធ្វើការតស៊ូមតិចំពោះការកែសម្រួលណាមួយដែលចាំបាច់។

## លទ្ធផល

សេវាកម្មរបស់យើងបានរៀបចំឡើង ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់លាក់ និងគោលបំណងរបស់អាណាព្យាបាលម្នាក់ៗ។ យើងជួយសម្រួលដល់ការសម្រេចគោលដៅរបស់ពួកគាត់ តាមរយៈការផ្តល់ការពិគ្រោះយោបល់ ការបង្កើតទំនាក់ទំនងជាមួយសេវាកម្មសហគមន៍ និងការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ ដែលក្នុងនោះរួមមាន៖

- ការជួយលើតម្រូវការជាក់ស្តែង ដូចជា សម្ភារៈបណ្តុះបណ្តាល ជំនួយក្នុងការចិញ្ចឹមបីបាច់កូន និងមធ្យោបាយធ្វើដំណើរ។
- ការសម្រួលលទ្ធភាពទទួលបានសេវាកម្មមូលដ្ឋានប្រកបដោយគុណភាព។
- ការឧបត្ថម្ភដល់អាណាព្យាបាលក្នុងការសម្រេចគោលបំណងផ្នែកការសិក្សាអប់រំ និងការបង្កើនគុណវុឌ្ឍិ។
- ជួយធានាបាននូវឱកាសការងារស្ម័គ្រចិត្ត ការងារទទួលបានប្រាក់ខែ និងការអភិវឌ្ឍអាជីព។
- ការលើកកម្ពស់ទំនុកចិត្ត និងការបណ្តុះកម្លាំងចិត្ត ព្រមទាំងការផ្តល់នូវការលើកទឹកចិត្ត និងការទទួលស្គាល់នូវរាល់សមិទ្ធផល។
- ជួយនិយោជកក្នុងស្រុកបំពេញតម្រូវការកម្លាំងពលកម្មរបស់ពួកគេ តាមរយៈបេក្ខជនកម្មវិធី Parent Pathways។

## ការចូលរួម/តំណភ្ជាប់

យើងចាប់ដៃគូជាមួយសេវាកម្មក្នុងមូលដ្ឋាន អ្នកផ្តល់ការបណ្តុះបណ្តាល និងអង្គការវប្បធម៌ជាច្រើន។ យើងខ្ញុំចែករំលែកចំណេះដឹងរវាងគ្នានឹងគ្នា ដើម្បីពង្រឹងការគាំទ្រសម្រាប់សហគមន៍ចម្រុះនានានៅ Western Melbourne។ យើងជ្រើសរើសអ្នកផ្តល់ជំបូន្មានពីសហគមន៍មូលដ្ឋាន ហើយផ្តល់ការបណ្តុះបណ្តាលបន្ត ដើម្បីពង្រឹងជំនាញរបស់ពួកគេ។

## ការចូលប្រើសេវាកម្ម និងធនធាន

យើងដំណើរការនៅតាមទីតាំងជាច្រើន។ អ្នកផ្តល់ជំបូន្មានក៏អាចជួបមាតាបិតានៅតាមទីតាំង ដែលបានព្រមព្រៀងគ្នាផងដែរ ដូចជាកន្លែងការងារ ឬមជ្ឈមណ្ឌលផ្តល់សេវាកម្ម។ ទីតាំងរបស់យើងមានលក្ខណៈមិនផ្លូវការ និងរួសរាយសម្រាប់កុមារ រួមទាំងមានប្រដាប់ក្មេងលេង និងសកម្មភាពសម្រាប់កុមារផងដែរ។

## យុទ្ធសាស្ត្រកម្លាំងពលកម្ម

ក្រុមការងាររបស់យើង រួមមានអ្នកផ្តល់ជំបូន្មាន អ្នកគ្រប់គ្រងគេហទំព័រ និងអ្នកសម្របសម្រួលការចូលរួម ដែលពួកគេម្នាក់ៗ នាំមកនូវបទពិសោធន៍ចម្រុះផ្នែកវប្បធម៌ មុខរបរ និងជំនាញឯកទេស។ អ្នកផ្តល់ជំបូន្មាន និងអ្នកផ្តល់ជំបូន្មានជាន់ខ្ពស់ អាចជួយគាំទ្រដល់មាតាបិតាបានរហូតដល់ 50 នាក់ក្នុងពេលតែមួយ។ ប្រធានគ្រប់គ្រងទីតាំងត្រួតពិនិត្យប្រតិបត្តិការក្នុងមូលដ្ឋាន ចំណែកឯអ្នកសម្របសម្រួលការចូលរួមធានាថា បណ្តាញដៃគូសេវាកម្មក្នុងស្រុកបំពេញeតាមតម្រូវការរបស់មាតាបិតា។ រាល់បុគ្គលិកទាំងអស់ ទទួលបានការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពវិជ្ជាជីវៈជាបន្តបន្ទាប់។

## ត្រូវការជំនួយមែនទេ? យើងប្រចាំការនៅទីនេះដើម្បីជួយ

☏ 136 123

www.employmentplus.com.au

# WESTERN MELBOURNE REGION SITE LOCATIONS

| Service Area | Site Address | Type | Opening Hours |
|---|---|---|---|
| Manor Lakes | 86 Manor Lakes Boulevard,<br>Manor Lakes, VIC, 3024 | Outreach | By appointment |
| Werribee | 5 Pine Avenue,<br>Werribee, VIC, 3030 | Full-Time | Monday-Friday,<br>9am - 5pm |
| Hoppers Crossing | 80 Lonsdale Circuit,<br>Hoppers Crossing, VIC, 3029 | Full-Time | Monday - Friday,<br>9am - 5pm |
| Altona Meadows | 2 Newham Way,<br>Altona Meadows, VIC, 3028 | Outreach | By appointment |
| Altona North | 7 Plover Drive,<br>Altona North, VIC, 3025 | Outreach | By appointment |


ត្រូវការជំនួយមែនទេ? យើងប្រចាំការនៅទីនេះដើម្បីជួយ

☏ 136 123

www.employmentplus.com.au